លេខ ៣៧ ចេញផ្សាយថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែមិថុនា ឆ្នាំ២០២៤

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## សន្និសីទ Alpine ប្រចាំឆ្នាំ២០២៤ ស្ដីពី "ទ្រព្យសម្បត្តិឯកជន៖ ការតជំនាន់ និងបច្ចេកវិទ្យា"

កាលពីថ្ងៃអង្គារ ១៤កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក រិន វីរៈ** ប្រធានការិយាល័យនីតិកម្មនៃនាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច បានចូលរួម "សន្និសីទ Alpine ប្រចាំឆ្នាំ២០២៤" ស្ដីពី "ទ្រព្យសម្បត្តិឯកជន៖ ការតជំនាន់ និងបច្ចេកវិទ្យា" ដែលរៀបចំដោយសហព័ន្ធ Society of Trust and Estate Practitioners (STEP) នៃប្រទេសស្វីស និងលិចតិចស្តាញ នៅសភា Congress Kursaal Interlaken នៃប្រទេសស្វីស និងមានរយៈពេល ៣ថ្ងៃ ក្នុងគោលបំណងដើម្បីដកស្រង់បទពិសោធ និងសិក្សាឈ្វេងយល់អំពីក្របខណ្ឌបទប្បញ្ញត្តិ ឧត្តមានុវត្តន៍អន្តរជាតិ និងឌីជីថលភាវូបនីយកម្ម/បញ្ញាសិប្បនិម្មិតក្នុងវិស័យបរធនបាលកិច្ច។

កម្មវិធីនេះមានការអញ្ជើញចូលរួមជាអធិបតីពី **លោកស្រី Kelly Greig** ប្រធាន STEP ពិភពលោក និងមានការអញ្ជើញចូលរួមពី លោក Andrew McCallum ប្រធានសហព័ន្ធ STEP នៃប្រទេសស្វីស និងលិចតិចស្តាញ ព្រមទាំងសិក្ខាកាមដែលជាអ្នកជំនាញជាន់ខ្ពស់ពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ចមកពីសហរដ្ឋ-អាមេរិក, ចក្រភពអង់គ្លេស និងបណ្ដាប្រទេសក្នុងទ្វីបអឺរ៉ុប សរុបចំនួនប្រមាណជា ២៥០រូប។

## មាតិកា


- សន្និសីទ Alpine ប្រចាំឆ្នាំ២០២៤ ស្ដីពី "ទ្រព្យសម្បត្តិឯកជន÷ ការតជំនាន់ និងបច្ចេកវិទ្យា" ទំព័រទី១
- ការចុះជួបអតិថិជនបានទទួលប្រាក់កម្ចី និងប្រជុំការងារជាមួយសាខាធនាគារតាមខេត្តនីមួយៗ នៃការអនុវត្តគម្រោង ACSEP ទំព័រទី២
- កិច្ចប្រជុំក្រុមការងារអន្តរក្រសួង ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឱ្យជនបរទេសមិនមែនអន្តោប្រវេសន៍ ចូល ចេញ និងស្នាក់នៅព្រះរាជាណាចក្រកម្ពុជា ទំព័រទី២
- កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទំព័រទី៣
- សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ទំព័រទី៣
- កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំខែឧសភា ឆ្នាំ២០២៤ របស់នាយកដ្ឋានកិច្ចការទូទៅ ទំព័រទី៣
- កិច្ចប្រជុំផ្សព្វផ្សាយអំពីបច្ចុប្បន្នភាពនៃការអនុវត្តយន្តការធានាឥណទាន ទំព័រទី៤
- កិច្ចប្រជុំផ្សព្វផ្សាយសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៥-២០២៧ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ ទំព័រទី៤
- សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ទំព័រទី៥
- កិច្ចប្រជុំពិភាក្សាការងាររវាង **ន.ប.ធ.** និងថ្នាក់ដឹកនាំនៃធនាគារ វឌ្ឍនៈ ទំព័រទី៥
- សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍" នៅខេត្តព្រះវិហារ ទំព័រទី៥
- កិច្ចប្រជុំស្តីពី "ការរៀបចំធ្វើបច្ចុប្បន្នភាពឯកសារគាំទ្រក្នុងគម្រោង ACSEP" ទំព័រទី៦
- កិច្ចប្រជុំត្រីភាគីស្តីពី "ការពិនិត្យឡើងវិញលើវឌ្ឍនភាពការអនុវត្តគម្រោង/កម្មវិធីក្រោមក្របខណ្ឌហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB)" ទំព័រទី៧
- ការផ្សព្វផ្សាយការងារពាក់ព័ន្ធនឹងផលិតផលឥណទានក្នុងគម្រោង ACSEP ដល់សមាជិកសហគមន៍ ទំព័រទី៧
- កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទំព័រទី៨
- កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" ទំព័រទី៨
- កម្មវិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** និងវិទ្យាស្ថានហិរញ្ញវត្ថុនិងគណនេយ្យ ទំព័រទី៨
- កិច្ចពិភាក្សាការងាររវាង **ន.ប.ធ.** ជាមួយក្រុមប្រតិភូវិនិយោគិនអញ្ជើញមកពីទីក្រុងសៀងហៃ ប្រទេសចិន ទំព័រទី៩
- ការបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់អគារសាលាបឋមសិក្សាថ្មី ទំព័រទី៩
- សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ទំព័រទី១០
- សិក្ខាសាលាស្តីពី "ការជំរុញការប្រើប្រាស់ និងការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ" ទំព័រទី១០
- កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" ទំព័រទី១០
- ពិធី "ប្រកាសដាក់ឱ្យប្រើប្រាស់ FMIS ជំនាន់ថ្មីជាផ្លូវការ និងប្រើប្រាស់សាកល្បងកម្មវិធីកញ្ចប់ថវិកាតាមទូរសព្ទដៃជំនាន់ទី១ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ" ទំព័រទី១១
- សិក្ខាសាលាស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" ទំព័រទី១១




អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




រូបភាព៖ សន្និសីទ Alpine ប្រចាំឆ្នាំ២០២៤ ស្តីពី "ទ្រព្យសម្បត្តិឯកជន៖ ការតជំនាន់ និងបច្ចេកវិទ្យា"។

## ការចុះជួបអតិថិជនបានទទួលប្រាក់កម្ចី និងប្រជុំការងារជាមួយសាខាធនាគារតាមខេត្តនីមួយៗ នៃការអនុវត្តគម្រោង ACSEP

កាលពីថ្ងៃទី២៧-៣១ ខែឧសភា ឆ្នាំ២០២៤ ក្រុមការងាររបស់និយ័តករបរធនបាលកិច្ច អង្គភាពអនុវត្តគម្រោងសមាសភាគទី១ នៃគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP-PIU1) ដែលដឹកនាំដោយ **លោក ហេង សំអុល** បានចូលរួមជាមួយក្រុមការងារទីប្រឹក្សាគម្រោង (PIC Output 1&2) អង្គភាពអនុវត្តគម្រោងថ្នាក់ខេត្ត (PPIUs) និងធនាគារ ARDB និងស្ថាបនា (PFIs) បានចុះជួបអតិថិជនបានទទួលប្រាក់កម្ចី និងប្រជុំការងារជាមួយសាខាធនាគារតាមខេត្តនីមួយៗ។ ព្រមទាំងផ្ទៀងផ្ទាត់ការអនុវត្តទម្រង់ព័ត៌មានប្រព័ន្ធគ្រប់គ្រងសង្គមនិងបរិស្ថាន (ESMS)។ ក្រុមការងារបានចុះជួបអតិថិជនដែលចូលរួមក្នុងគម្រោងនៅខេត្តត្បូងឃ្មុំ កំពង់ចាម និងកំពង់ធំ ដែលក្នុងនោះមាន សហគមន៍កសិកម្ម, សមាជិកសហគមន៍កសិកម្ម និងកសិករចិញ្ចឹមមាន់ស្រុក។ ផលិតផលកសិកម្ម មានដូចជា ស្វាយចន្ទី បន្លែ មាន់ស្រុក និងដំឡូងមី។ អតិថិជនទាំងអស់នោះ បានប្រើប្រាស់ប្រាក់កម្ចីពីគម្រោង ACSEP តាមផែនការប្រើប្រាស់ប្រាក់កម្ចីដាក់ជាមួយធនាគារដៃគូចូលរួម។ កិច្ចប្រជុំជាមួយសាខាធនាគារ ផ្តោតសំខាន់ (១) បច្ចុប្បន្នភាពលទ្ធផលឥណទាន (២) បញ្ហាប្រឈមនានា និង (៣) ផែនការបង្កើនផលិតភាពតាមសាខា។ បញ្ហាប្រឈមធំៗ២ដែលធនាគារទាំងពីរជួបគឺ ទ្រព្យតម្កល់ធានាប្រាក់កម្ចី និងជាប់កម្ចីជាមួយធនាគារផ្សេងៗ។ បេសកកម្មបានបញ្ចប់តាមការគ្រោងទុក។




រូបភាព៖ ការចុះជួបអតិថិជនបានទទួលប្រាក់កម្ចី និងប្រជុំការងារជាមួយសាខាធនាគារតាមខេត្តនីមួយៗ នៃការអនុវត្តគម្រោង ACSEP។

## កិច្ចប្រជុំក្រុមការងារអន្តរក្រសួង ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឱ្យជនបរទេសមិនមែនអន្តោប្រវេសន៍ ចូល ចេញ និងស្នាក់នៅព្រះរាជាណាចក្រកម្ពុជា

នារសៀលថ្ងៃអង្គារ ១៣ រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៤ **លោកស្រី ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច និងសហការី បានចូលរួមកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ក្រោមការដឹកនាំរបស់ **ឯកឧត្តមសន្តិបណ្ឌិត គៀត ច័ន្ទថារិទ្ធ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឱ្យជនបរទេសមិនមែនអន្តោប្រវេសន៍ ចូល ចេញ និងស្នាក់នៅព្រះរាជាណាចក្រកម្ពុជា ដោយមានការចូលរួមពីតំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, តំណាងក្រសួងទេសចរណ៍ និងតំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។




រូបភាព៖ កិច្ចប្រជុំក្រុមការងារអន្តរក្រសួង ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឱ្យជនបរទេសមិនមែនអន្តោប្រវេសន៍ ចូល ចេញ និងស្នាក់នៅព្រះរាជាណាចក្រកម្ពុជា។

## កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

នាព្រឹកថ្ងៃពុធ ១៤រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយ-ការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ Zoom។



**រូបភាព៖** កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

នាព្រឹកថ្ងៃពុធ ១៤រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៥ខែមិថុនា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យន័រតុនបានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច និង **លោកបណ្ឌិត** Van S. Dalluay ព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រសង្គមនៃសាកលវិទ្យាល័យន័រតុន នៅសាកលវិទ្យាល័យន័រតុន។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យន័រតុន។



**រូបភាព៖** សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"។

## កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំខែឧសភា ឆ្នាំ២០២៤ របស់នាយកដ្ឋានកិច្ចការទូទៅ

នាព្រឹកថ្ងៃព្រហស្បតិ៍ ១៥រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៤ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃ **ន.ប.ធ.** បានដឹកនាំកិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំខែឧសភា ឆ្នាំ២០២៤ របស់នាយកដ្ឋានកិច្ចការទូទៅ។

កិច្ចប្រជុំនេះ មានការចូលរួមពីប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យ និងមន្ត្រីជំនាញនៃនាយកដ្ឋាន។

ជាមួយគ្នានេះ ឯកឧត្តមអគ្គនាយករង បានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែឧសភា ឆ្នាំ២០២៤ ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋាន និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារបន្តផងដែរ។



រូបភាព៖ កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំខែឧសភា ឆ្នាំ២០២៤ របស់នាយកដ្ឋានកិច្ចការទូទៅ។

## កិច្ចប្រជុំផ្សព្វផ្សាយអំពីបច្ចុប្បន្នភាពនៃការអនុវត្តយន្តការធានាឥណទាន (CGF)

កាលពីថ្ងៃព្រហស្បតិ៍ ១៥រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៦ ខែមិថុនាឆ្នាំ២០២៤ និយ័តករបរធន-បាលកិច្ច (**ន.ប.ធ.**) ដែលជាអង្គភាពអនុវត្តគម្រោងស្តីពីការប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាគទី១ ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអំពីបច្ចុប្បន្នភាពនៃការអនុវត្តយន្តការធានាឥណទាន (CGF)។ កិច្ចប្រជុំនេះ ដឹកនាំដោយ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1 ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រី PIU1 សាជីវកម្មធានាឥណទានកម្ពុជា (CGCC) ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) និងធនាគារស្ថាបនា (SPNB)។ កិច្ចប្រជុំនេះ មានគោលបំណងដើម្បីធ្វើការផ្សព្វផ្សាយដល់ស្ថាប័នហិរញ្ញវត្ថុទាំងពីរអំពីការប្រែប្រួលនៃយន្តការអនុវត្តធានាឥណទានក្នុងក្របខណ្ឌគម្រោង ACSEP ដោយផ្នែកនេះ ត្រូវបានប្តូរឱ្យអនុវត្តដោយសាជីវកម្មធានាឥណទានកម្ពុជា (CGCC) វិញ ដោយប្រើប្រាស់នូវធនធាន និងប្រភពទុនផ្ទាល់របស់ CGCC។ កិច្ចប្រជុំបានដំណើរការប្រកបដោយភាពរលូន ជាមួយនឹងការធ្វើបទបង្ហាញអំពីវឌ្ឍនភាពនៃការរៀបចំសកម្មភាពសម្រាប់គាំទ្រប្រតិបត្តិការ CGF របស់ PIU1 នាពេលកន្លងមក និងមានការធ្វើបទបង្ហាញអំពីយន្តការ នីតិវិធី និងលក្ខខណ្ឌផ្សេងៗ ក្នុងការប្រតិបត្តិធានាឥណទានពីក្រុមការងាររបស់ CGCC ផងដែរ។



រូបភាព៖ កិច្ចប្រជុំផ្សព្វផ្សាយអំពីបច្ចុប្បន្នភាពនៃការអនុវត្តយន្តការធានាឥណទាន (CGF)។

## កិច្ចប្រជុំផ្សព្វផ្សាយសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៥-២០២៧ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥

នាព្រឹកថ្ងៃសុក្រ ១កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៤ **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៥-២០២៧ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាពក្រោមឱវាទ **កសហវ** និងមន្ទីរសេដ្ឋកិច្ចរាជធានី-ខេត្ត នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



រូបភាព៖ កិច្ចប្រជុំផ្សព្វផ្សាយសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៥-២០២៧ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥។

## សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

នាព្រឹកថ្ងៃចន្ទ ៤កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង **ឯកឧត្តម ហម សារ៉េត** នាយកសាខា នៃសាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា នៅសាកលវិទ្យាល័យ ឯកទេសនៃកម្ពុជា (ខេត្តកំពត)។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, **លោក ឈុន វិចិត្រ** នាយកសេវាធនាគាររូបវន្តបុគ្គលនៃធនាគារវឌ្ឍនៈអាស៊ីចំកាត់ វាគ្មិនតំណាងពីធនាគារវឌ្ឍនៈអាស៊ីចំកាត់, សាស្ត្រាចារ្យ, និងនិស្សិតនៃសាកលវិទ្យាល័យ ឯកទេសនៃកម្ពុជា (ខេត្តកំពត)។



រូបភាព៖ សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"។

## កិច្ចប្រជុំពិភាក្សាការងាររវាង ន.ប.ធ. និងថ្នាក់ដឹកនាំនៃធនាគារ វឌ្ឍនៈ

នាព្រឹកថ្ងៃអង្គារ ៥កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោក ហាយ សុវណ្ណា** ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច និងសហការីបានទទួលជួបប្រជុំពិភាក្សាជាមួយថ្នាក់ដឹកនាំនៃធនាគារ វឌ្ឍនៈ ដែលដឹកនាំដោយ **លោក អេនតូនី ជីន** អគ្គនាយកប្រតិបត្តិនៃធនាគារ វឌ្ឍនៈ និងសហការី ក្នុងគោលបំណងដើម្បីឆ្វេងយល់ពីវឌ្ឍនភាពនៃការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជា កាលានុវត្តភាព និងសក្តានុពលនៃយន្តការបរធនបាលកិច្ច ជាពិសេសសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច។



រូបភាព៖ កិច្ចប្រជុំពិភាក្សាការងាររវាង **ន.ប.ធ.** និងថ្នាក់ដឹកនាំនៃធនាគារ វឌ្ឍនៈ។

## សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍" នៅខេត្តព្រះវិហារ

នាថ្ងៃពុធ ៦ កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍" នៅខេត្តព្រះវិហារ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច តំណាង **ឯកឧត្តម សុខ ដារ៉ា**

អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1 និង **ឯកឧត្តម យុខ គឹមហ៊ាន** អភិបាលរង នៃគណៈអភិបាលខេត្តព្រះវិហារ។

កម្មវិធីនេះត្រូវបានរៀបចំនៅសហគមន៍ចំនួន ២ រួមមាន៖ សហគមន៍កសិកម្មលើកកម្ពស់កសិករ និងសហគមន៍កសិកម្មសាមគ្គីភ្នំពេជ្របុរី ក្នុងគោលបំណងធ្វើការណែនាំបន្ថែមដល់សមាជិកសហគមន៍ និងភ្នាក់ងារឥណទានគម្រោង ACSEP តាមខេត្ត ស្រុក និងឃុំគោលដៅ, ផ្តល់ព័ត៌មានអំពីការផ្តល់ប្រាក់កម្ចី របស់គម្រោង ACSEP ដល់សមាជិកសហគមន៍កសិកម្មដែលមានក្នុងបញ្ជីក្រុមគោលដៅ និងកសិករចិញ្ចឹមមាន់ស្រុក និងបង្ហាញអំពីនីតិវិធីដែលអាចទទួលបានឥណទានដល់សមាជិកសហគមន៍កសិកម្មដែលមានបំណងស្វែងរកទុនគាំទ្រផែនការអាជីវកម្មលើវិស័យកសិកម្ម។

កម្មវិធីនេះ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះវិហារ, តំណាងអភិបាលស្រុក និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងធនាគារស្ថាបនា។



**រូបភាព៖** សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍" នៅខេត្តព្រះវិហារ។

## កិច្ចប្រជុំស្តីពី "ការរៀបចំធ្វើបច្ចុប្បន្នភាពឯកសារគាំទ្រក្នុងគម្រោង ACSEP"

រសៀលថ្ងៃព្រហស្បតិ៍ ៧កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤ នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និយ័តករបរធនបាលកិច្ច (**ន.ប.ធ**) ដែលជាអង្គភាពអនុវត្តគម្រោង ACSEP សមាសភាគទី១ បានរៀបចំកិច្ចប្រជុំស្តីពី "ការរៀបចំធ្វើបច្ចុប្បន្នភាពឯកសារគាំទ្រក្នុងគម្រោង ACSEP" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**ក.ស.ហ.វ.**) និងជានាយកគម្រោង ACSEP សមាសភាគទី១ ដោយមានការចូលរួមពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោង ACSEP សមាសភាគទី១, **លោកស្រី Hyunyoung Song** ប្រធានក្រុមការងារធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទទួលបន្ទុកគម្រោង ACSEP និងសហការី, **លោក Wong Keet Loong** នាយកប្រតិបត្តិសាជីវកម្មធានាឥណទានកម្ពុជា និងសហការី,សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, តំណាងមកពីអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**ក.ស.ហ.វ.**), និងតំណាងអង្គភាពគ្រប់គ្រងគម្រោងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។



**រូបភាព៖** កិច្ចប្រជុំស្តីពី "ការរៀបចំធ្វើបច្ចុប្បន្នភាពឯកសារគាំទ្រក្នុងគម្រោង ACSEP"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំត្រីភាគីស្តីពី "ការពិនិត្យឡើងវិញលើវឌ្ឍនភាពការអនុវត្តគម្រោង/កម្មវិធីក្រោមក្របខណ្ឌហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB)"

នាព្រឹកថ្ងៃសុក្រ ៨កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោង ACSEP នៃសមាសភាគទី១ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **លោក ហាយ សុវណ្ណា** ប្រធានស្តីទីនៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច នៃ **ន.ប.ធ.** និងជាប្រធានផ្នែកគណនេយ្យនិងហិរញ្ញវត្ថុ និង **លោក មៀច សុគន្ធ** ទីប្រឹក្សាជាតិផ្នែកហិរញ្ញវត្ថុ នៃគម្រោង ACSEP បានចូលរួមកិច្ចប្រជុំត្រីភាគីស្តីពី "ការពិនិត្យឡើងវិញលើវឌ្ឍនភាពការអនុវត្តគម្រោង/កម្មវិធីក្រោមក្របខណ្ឌហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB)" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ែន ធីរុទ្ធ** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង **លោក Anthony Gill** ប្រធាន ADB ប្រចាំនៅកម្ពុជា ដោយមានការអញ្ជើញចូលរួមដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ (ZOOM) ពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន ដែលជាអង្គភាពគ្រប់គ្រងគម្រោង និងអង្គភាពអនុវត្តគម្រោងក្រោមហិរញ្ញប្បទានរបស់ ADB។



**រូបភាព៖** កិច្ចប្រជុំត្រីភាគីស្តីពី "ការពិនិត្យឡើងវិញលើវឌ្ឍនភាពការអនុវត្តគម្រោង/កម្មវិធីក្រោមក្របខណ្ឌហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB)"។

## ការផ្សព្វផ្សាយការងារពាក់ព័ន្ធនឹងផលិតផលឥណទានក្នុងគម្រោង ACSEP ដល់សមាជិកសហគមន៍

ចាប់ពីថ្ងៃព្រហស្បតិ៍ ៧ កើត ដល់ថ្ងៃសុក្រ ៨ កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៣-១៤ ខែមិថុនា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP-PIU1) ក្រោមក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបន្តការងារផ្សព្វផ្សាយពាក់ព័ន្ធនឹងផលិតផលឥណទានក្នុងគម្រោងដល់សមាជិកសហគមន៍ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤ ដល់សហគមន៍កសិកម្មរំដួលល្អព្រៃជាយដែន និងនៅថ្ងៃទី១៤ខែមិថុនា ឆ្នាំ២០២៤ ដល់សហគមន៍កសិកម្មរស្មីលើកកម្ពស់កសិករ និងសហគមន៍កសិកម្មសាមគ្គីរហ័សមានជ័យ នៅខេត្តព្រះវិហារ។

កម្មវិធីនេះត្រូវបានរៀបចំក្នុងគោលបំណងធ្វើការណែនាំបន្ថែមដល់សមាជិកសហគមន៍ និងភ្នាក់ងារឥណទានគម្រោង ACSEP តាមខេត្ត ស្រុក និងឃុំគោលដៅ, ផ្តល់ព័ត៌មានអំពីការផ្តល់ប្រាក់កម្ចី របស់គម្រោង ACSEP ដល់សមាជិកសហគមន៍កសិកម្មដែលមានក្នុងបញ្ជីក្រុមគោលដៅ និងកសិករចិញ្ចឹមមាន់ស្រុក និងបង្ហាញអំពីនីតិវិធីដែលអាចទទួលបានឥណទានដល់សមាជិកសហគមន៍កសិកម្ម ដែលមានបំណងស្វែងរកទុនគាំទ្រផែនការអាជីវកម្មលើវិស័យកសិកម្ម។

កម្មវិធីខាងលើ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះវិហារ, អភិបាលរងស្រុក, ក្រុមប្រឹក្សាឃុំ និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



**រូបភាព៖** ការផ្សព្វផ្សាយការងារពាក់ព័ន្ធនឹងផលិតផលឥណទានក្នុងគម្រោង ACSEP ដល់សមាជិកសហគមន៍។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

នាព្រឹកថ្ងៃពុធ ១៣កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណារី សាគល** អគ្គនាយករងនៃ **ន.ប.ធ.**, **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេស TWG ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន តំណាងដៃគូអភិវឌ្ឍន៍ តំណាងអង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ Zoom។



រូបភាព៖ កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា"

នារសៀលថ្ងៃព្រហស្បតិ៍ ១៤កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី (CIMB) បានសហការគ្នារៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង **លោក ប៊ុន យឺន** ប្រធាននាយកប្រតិបត្តិនៃធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារ សុខា ភ្នំពេញ។ កម្មវិធីបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើង ក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងបន្ថែមអំពីយន្តការបរធនបាលកិច្ចនៅកម្ពុជា ដល់ថ្នាក់ដឹកនាំ និងបុគ្គលិកទទួលបន្ទុកមកពីទីស្នាក់ការកណ្តាល និងបណ្តាសាខារបស់ធនាគារ CIMB នៅរាជធានីភ្នំពេញ ដែលធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងបរធនបាលកិច្ច ក៏ដូចជាអតិថិជនរបស់ធនាគារ CIMB ដែលជាធនាគារទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ធ្វើជាក្រុមហ៊ុនបរធនបាលធ្វើប្រតិបត្តិការគ្រប់គ្រង, ចាត់ចែង និងប្រតិបត្តិការរក្សាសុវត្ថិភាព ឬរក្សាទុក សម្រាប់ប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម។



រូបភាព៖ កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា"។

## កម្មវិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) និងវិទ្យាស្ថានហិរញ្ញវត្ថុនិងគណនេយ្យ

នារសៀលថ្ងៃព្រហស្បតិ៍ ១៤កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ **ឯកឧត្តម ណារី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** បានអញ្ជើញចូលរួមជាអធិបតីក្នុង "កម្មវិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងវិទ្យាស្ថានហិរញ្ញវត្ថុនិងគណនេយ្យ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** នៅអគារ **អ.ស.ហ.**។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



**រូបភាព៖** កម្មវិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ។

## កិច្ចពិភាក្សាការងាររវាង ន.ប.ធ. ជាមួយក្រុមប្រតិភូវិនិយោគិនអញ្ជើញមកពីទីក្រុងសៀងហៃ ប្រទេសចិន

នារសៀលថ្ងៃសុក្រ ១៥កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោក ហាយ សុវណ្ណា** ប្រធានស្តីទីនៃនាយកដ្ឋានចុះបញ្ជីបរធន-បាលកិច្ច និងសហការី បានស្វាគមន៍ និងអញ្ជើញទទួលជួបពិភាក្សាការងារជាមួយក្រុមប្រតិភូវិនិយោគិនអញ្ជើញមកពីទីក្រុងសៀងហៃ ប្រទេសចិន ដែលក្នុងនោះមាន ថ្នាក់ដឹកនាំ និងតំណាងក្រុមហ៊ុន Huahong Financial Holding Group, ក្រុមហ៊ុន Xingling Didgital Technology, ក្រុមហ៊ុន Asia Pacific Pengsheng Finance and Taxation Group និង **លោកឧកញ៉ា ម៉ាន់ ច័ន្ទឌី** អគ្គនាយកនៃក្រុមហ៊ុន ព្រីមៀម ហៅហ្ស៊ីង។ កិច្ចប្រជុំនេះ បានពិភាក្សាទៅលើវឌ្ឍនភាពនៃកិច្ចដំណើរការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជា កាលានុវត្តភាពនៃការវិនិយោគតាមរយៈយន្តការបរធន-បាលកិច្ច ក៏ដូចជា ទិដ្ឋភាព និងកាលានុវត្តភាពនៃទីផ្សារហិរញ្ញវត្ថុនៅកម្ពុជាជារួមផងដែរ។



**រូបភាព៖** កិច្ចពិភាក្សាការងារជាមួយក្រុមប្រតិភូវិនិយោគិនអញ្ជើញមកពីទីក្រុងសៀងហៃ ប្រទេសចិន។

## ការបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់អគារសាលាបឋមសិក្សាថ្មី

នារសៀលថ្ងៃអាទិត្យ ២រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងលោកជំទាវ អម**ដោយ ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃ **ន.ប.ធ.**, **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់អគារសាលាបឋមសិក្សាថ្មី ១ខ្នង មាន ៤បន្ទប់ ដែលមានទីតាំងស្ថិតនៅភូមិប្រឡាយទ្រៀក ឃុំដំរីផុង ស្រុកឆ្លូង ខេត្តក្រចេះ។

កម្មពិធីនេះមានការចូលរួមពី លោកអភិបាលរងស្រុកឆ្លូង, លោកប្រធានការិយាល័យអបរំស្រុកឆ្លូង, លោកស្រីមេឃុំដំរីផុង និងអាជ្ញាធរពាក់ព័ន្ធ ព្រមទាំងប្រជាជនក្នុងភូមិប្រឡាយទ្រៀក ក៏ដូចជាមាតា បិតា អាណាព្យាបាល និងសិស្សានុសិស្សផងដែរ។

ការសាងសង់អគារសាលាបឋមសិក្សាថ្មីក្រោមការផ្តួចផ្តើមពីនិយ័តករបរធនបាលកិច្ចនេះ ជំនួសឲ្យអគារសាលាបឋមសិក្សាចាស់ដែលទ្រុឌទ្រោម មានការចូលរួមឧបត្ថម្ភគាំទ្រពីបរធនបាលកិច្ចហិរញ្ញវត្ថុប្រាសាក់ និងបរធនបាលកិច្ចហិរញ្ញវត្ថុហត្ថាកសិករ។

ជាមួយគ្នានេះ ក្រុមការងារ **ន.ប.ធ.** ក៏មានការផ្តល់ជូនអំណោយ និងសម្ភារៈសិក្សាមួយចំនួន ដល់លោកតា លោកយាយចាស់ភូមិ និងសិស្សានុសិស្សផងដែរ។



**រូបភាព៖** ការបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់អគារសាលាបឋមសិក្សាថ្មី។

## សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

នាព្រឹកថ្ងៃចន្ទ ៣រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យក្រចេះ បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង **ឯកឧត្តមបណ្ឌិត ទី ឡាយមិថុនា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យក្រចេះ នៅសាកលវិទ្យាល័យក្រចេះ។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, **លោក ស៊ីយ៉ា ម៉ាលីជា** នាយកការិយាល័យប្រតិបត្តិការមូលបត្រ និងបរធនបាលកិច្ចនៃធនាគារអេស៊ីលីដា ភីអិលស៊ី វាគ្មិនតំណាងពីធនាគារអេស៊ីលីដា ភីអិលស៊ី, សាស្ត្រាចារ្យ, និស្សិតនៃសាកលវិទ្យាល័យក្រចេះ និងលោកគ្រូអ្នកគ្រូ សិស្សមកពីវិទ្យាល័យសម្តេចតេជោហ៊ុនសែនក្រចេះក្រុង វិទ្យាល័យព្រះមហាក្សត្រីយានីកុសុមៈ និងវិទ្យាល័យ ខូវប៊ុនស៊ុនក្រចេះក្រុង ផងដែរ។



**រូបភាព៖** សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"។

## សិក្ខាសាលាស្តីពី "ការជំរុញការប្រើប្រាស់ និងការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ"

នាព្រឹកថ្ងៃអង្គារ ៤រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤ **ឯកឧត្តម ណី សារាល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងសហការីបានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី "ការជំរុញការប្រើប្រាស់ និងការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម គុយ សាវុធ** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** និងមានការអញ្ជើញចូលរួមពីនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.**, ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន នៅទីស្តីការ **អ.ស.ហ.**។



**រូបភាព៖** សិក្ខាសាលាស្តីពី "ការជំរុញការប្រើប្រាស់ និងការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ"។

## កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា"

នាព្រឹកថ្ងៃអង្គារ ៤រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងក្រុមហ៊ុន ស្ទ្រងហូល ត្រាសធី ឯ.ក បានសហការគ្នារៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងចូលរួមដោយ **លោក Chen Han En** នាយកប្រតិបត្តិនៃក្រុមហ៊ុន ស្ទ្រងហូល ត្រាសធី ឯ.ក ដែលបានប្រព្រឹត្តទៅនៅអគារ Morgan Tower រាជធានីភ្នំពេញ។ កម្មវិធីបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងបន្ថែម



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

អំពីយន្តការបរធនបាលកិច្ចអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៅកម្ពុជា ដល់ថ្នាក់ដឹកនាំ និងបុគ្គលិកទទួលបន្ទុកមកពីក្រុមហ៊ុន ស្រ្តងហ្វូល ត្រាសធី ឯ.ក ដែលជាក្រុមហ៊ុនបរធនបាលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ធ្វើប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម និងបុគ្គលក៏ដូចជាក្រុមហ៊ុនដៃគូរបស់ក្រុមហ៊ុន ស្រ្តងហ្វូល ត្រាសធី ឯ.ក។



**រូបភាព៖** កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា"។

## ពិធី "ប្រកាសដាក់ឱ្យប្រើប្រាស់ FMIS ជំនាន់ថ្មីជាផ្លូវការ និងប្រើប្រាស់សាកល្បងកម្មវិធីកញ្ចប់ថវិកាតាមទូរសព្ទដៃ ជំនាន់ទី១ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ"

នារសៀលថ្ងៃអង្គារ ៤រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤ **ឯកឧត្តម ណី សារាល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងសហការីបានអញ្ជើញចូលរួមពិធី "ប្រកាសដាក់ឱ្យប្រើប្រាស់ FMIS ជំនាន់ថ្មីជាផ្លូវការ និងប្រើប្រាស់សាកល្បងកម្មវិធីកញ្ចប់ថវិកាតាមទូរសព្ទដៃ ជំនាន់ទី១ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាពក្រោមឱវាទ កសហវ និងមន្ទីរសេដ្ឋកិច្ចរាជធានី-ខេត្ត នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញ ភូគីត្រា។



**រូបភាព៖** ពិធី "ប្រកាសដាក់ឱ្យប្រើប្រាស់ FMIS ជំនាន់ថ្មីជាផ្លូវការ និងប្រើប្រាស់សាកល្បងកម្មវិធីកញ្ចប់ថវិកាតាមទូរសព្ទដៃជំនាន់ទី១ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ"។

## សិក្ខាសាលាស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច"

នារសៀលថ្ងៃសៅរ៍ ៨ រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង **លោកបណ្ឌិត សឿន សោភ័ណ** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, សាស្ត្រាចារ្យ, និងនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានចំនួនសរុបប្រមាណ ៤០០ នាក់។



**រូបភាព៖** សិក្ខាសាលាស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច"។